ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ អង្គារ ៨ កើត ខែ ជេស្ឋ ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៩*

# សេចក្តីដំណឹងសម្រាប់សារព័ត៌មាន
## ស្តីពីជំនួបរវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយនឹងអនុប្រធានសភាពាណិជ្ជកម្មអឺរ៉ុបប្រចាំកម្ពុជា (EUROCHAM Cambodia)

នាព្រឹកថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, បានទទួលជួបសម្តែងការគួរសមជាមួយលោក Guillaume Massin អនុប្រធានសភាពាណិជ្ជកម្មអឺរ៉ុបប្រចាំកម្ពុជា (EUROCHAM) ក្នុងខណៈដែលលោក Guillaume Massin ប្រគល់នូវ "**សៀវភៅ ស ឆ្នាំ ២០១៩** (White Book 2019)" របស់ EUROCHAM ជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី បានសម្តែងនូវអំណរសាទរ និងវាយតម្លៃខ្ពស់ចំពោះសភាពាណិជ្ជកម្មអឺរ៉ុបប្រចាំកម្ពុជា ដែលទើបតែបានបោះពុម្ពផ្សាយនូវ "**សៀវភៅ ស ឆ្នាំ ២០១៩** (White Book 2019)" ដោយជោគជ័យ ក្នុងពេលថ្មីៗកន្លងមកនេះ ។ ជាមួយគ្នានេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ ចំពោះសភាពាណិជ្ជកម្មអឺរ៉ុបប្រចាំកម្ពុជា ដែលតែងតែបានរួមចំណែកធ្វើឱ្យកាន់តែប្រសើរឡើងនូវបរិយាកាសវិនិយោគនៅកម្ពុជា ជាមួយនឹងការផ្សព្វផ្សាយអំពីឱកាសវិនិយោគនៅកម្ពុជា ក៏ដូចជា ផ្តល់នូវមតិស្ថាបនា ចូលរួមចំណែកលើកកម្ពស់ភាពប្រកួតប្រជែង និងទាក់ទាញវិនិយោគមកកម្ពុជា ។

**លោក Guillaume Massin** អនុប្រធានសភាពាណិជ្ជកម្មអឺរ៉ុបប្រចាំកម្ពុជា បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយកម្ពុជា និងសូមកោតសរសើរចំពោះសមិទ្ធផលដែលកម្ពុជាទទួលបាននាពេលកន្លងមក ។ លោក ក៏បានថ្លែងអំណរគុណចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលបានផ្តល់នូវអនុសាសន៍ ក្នុងការចងក្រងសៀវភៅនេះឡើង ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាក្រសួងទី ១ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួល "**សៀវភៅ ស ឆ្នាំ ២០១៩**" នេះ ។ "**សៀវភៅ ស ឆ្នាំ ២០១៩**" មិនត្រឹមតែរំលេចនូវអនុសាសន៍នានាសម្រាប់រាជរដ្ឋាភិបាល ប៉ុន្តែក៏បានរំលេចនូវសមិទ្ធិផលដែលរាជរដ្ឋាភិបាលសម្រេចនាពេលកន្លងមក ។ ជាមួយគ្នានេះ, គោលបំណងចម្បងរបស់ "**សៀវភៅ ស ឆ្នាំ ២០១៩**" គឺចូលបញ្ជាក់ជូនវិនិយោគិនទាំងអស់ ទាំងវិនិយោគិនជាតិ និងអន្តរជាតិថា កម្ពុជាបានត្រៀមខ្លួនជាស្រេចសម្រាប់ការដាក់ទុកវិនិយោគ ។ លោក Guillaume Massin សង្ឃឹមថានឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា ដើម្បីចូលរួមចំណែកលើកកម្ពស់ភាពប្រកួតប្រជែង និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ។